# ន គ រ កា យ

## គតិធម៌ ធៀប គតិលោក

៙ ៙ ៙

## នមត្ថុ រតនត្តយស្ស

សូមនមស្ការចំពោះព្រះរតនត្រ័យ, ហើយសូមសំដែងធម្មកថា
ជាគតិធម៌ ធៀប គតិលោក ដូចតទៅនេះ :

**ឯកោ រាជា ចិត្តំ នាម នគរកាយេ រជ្ជំ ការេសិ ។ តស្ស អគ្គមហេសី អវិជ្ជា ទេវី នាម, បិតា មោហោ នាម, មាតា លោភទេវី នាម ។**

សាធុសប្បុរសទាំងឡាយ !

ក្នុងចិរន្តរកាល, មានព្រះរាជាមួយព្រះអង្គ ទ្រង់ព្រះនាមព្រះពាថ ចិត្តរាជ ជាបរមក្សត្រគ្រងរាជសម្បត្តិ ក្នុងព្រះនគរមួយឈ្មោះ នគរកាយ ។ ព្រះរាជាអង្គនោះមានព្រះអគ្គមហេសីទ្រង់ព្រះនាមព្រះនាង អវិជ្ជាទេវី ជាទីគាប់ព្រះម័យ

ជាងព្រះស្មុំទាំងពួង, ព្រះបិតាទ្រង់ព្រះនាមព្រះពាទ មៅហារាជ ព្រះមាតា ទ្រង់ព្រះនាមព្រះនាង លោភទេវី ។

ឯសរីរកាយនោះមានទ្វារ ៩ គឺ :

| | | |
|---|---|---|
| ចក្ខុទ្វារ | ( ទ្វារភ្នែក ) | ២ . |
| សោតទ្វារ | ( ទ្វារត្រចៀក ) | ២ . |
| ឃានទ្វារ | ( ទ្វារច្រមុះ ) | ២ . |
| ជិវ្ហាទ្វារ | ( ទ្វារមាត់ ) | ១ . |
| បស្សាវទ្វារ | ( ទ្វារតូច ) | ១ . |
| ឧច្ចារទ្វារ | ( ទ្វារធំ ) | ១ . ។ |

មានប្រាប្តប្រាសាទ ៥ គឺ :

១_ ចក្ខុប្រាសាទ ( ១ ) ជាព្រះទីនាំងសំរាប់ព្រះមហាក្សត្រទ្រង់ទតល្បែងរបាំទាំងពួង

១_ ត្រង់បទនេះ ក្នុងអភិធម្មសង្គហៈថា ចក្ខុបសាទ ។ បាន ជាក្នុងទីនេះថា ចក្ខុប្រាសាទ ព្រោះផ្សាគពិធមិ បៀប គពិ លោក។

២_ សោតប្រាសាទ ជាព្រះទីនាំងសំរាប់ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់សូរស័ព្ទតូរ្យតន្ត្រីទាំងពួង

៣_ ឃានប្រាសាទ ជាព្រះទីនាំងសំរាប់ព្រះមហាក្សត្រទ្រង់ព្រះសុគន្ធរស

៤_ ជីវ្ហាប្រាសាទ ជាព្រះទីនាំងសំរាប់ព្រះមហាក្សត្រទ្រង់សោយព្រះស្ងោយភោជនាហារដ៏មានឱជារស

៥_ កាយប្រាសាទ ជាព្រះទីនាំងសំរាប់ព្រះមហាក្សត្រទ្រង់គ្រឿងអលង្ការទាំងពួង ទាំងគ្រឿងបញ្ចក កុធភណ្ឌ ជាគ្រឿងសំរាប់រាជ្យជាដើម ។

ព្រះបាទចិត្តរាជ ព្រះអង្គមានមហាតល្លិក ៧ នាក់ ដែលទ្រង់តាំងក្នុងឋានន្តរស័ក្តិទីហ្លួង មានមុខងារផ្សេង ៗ គ្នា សម្រាប់ជារាជបម្រើតាមពេលដែលទ្រង់ត្រូវការគឺ

១_ ហ្លួងផងសេរ្យា ( ១ ) ជាអ្នកចាប់កាន់ព្រះអង្គ.

២_ ហ្លួងសញ្ញា ជាអ្នកចាំសំគាល់កិច្ចការទាំងពួងព្រះរាជាដែលទ្រង់ប្រើឱ្យសំគាល់ ;

---

១_ ចេតសិកទាំង ៧ នេះ ក្នុងអភិធម្មសង្គហៈ ហៅថាសព្វសាធារណចេតសិក ។

៣_ ហ្មឺនវេទនា ជាអ្នកណែនាំព្រះមហាក្សត្រឱ្យ សោយអារម្មណ៍ផ្សេង ៗ មានសុខជាដើម ,

៤_ ហ្មឺនចេតនា ជាអ្នកចាំទទួលព្រះរាជឱង្ការក្នុង កាលដែលព្រះរាជាត្រូវការប្រើទៅកាន់ទីណា ក៏ទៅដោយរហ័ស

៥_ ហ្មឺនឯកគ្គតា ជាអ្នកស្លុតត្រង់. ព្រះរាជាទ្រង់ ទុកព្រះទ័យជឿយកពាក្យ

៦_ ហ្មឺនមនសិការោ ជាអ្នកយកចិត្តទុកដាក់នូវកិច្ច ការផ្សេង ៗ ដែលព្រះរាជាទ្រង់ប្រើ,

៧_ ហ្មឺនជីវិតិន្ទ្រិយ ជាអ្នកជួយផ្គត់ផ្គង់ព្រះជន្ម ព្រះរាជាឱ្យមានព្រះជីវភាព ។

ព្រះបាទចិត្តរាជ ព្រះអង្គមានបុរោហិត ៣ រូប ទ្រង់តាំង ទុកក្នុងឋានន្តរស័ក្តិជារាជគ្រូ សម្រាប់ណែនាំព្រះអង្គក្នុងព្រះរាជ ពិធីផ្សេង ៗ តាមដែលទ្រង់ត្រូវការពី

១_ រាជគ្រូវិតក្កោ (១) ជាអ្នកណែនាំព្រះរាជា ឱ្យត្រិះរិះនូវកិច្ចការផ្សេង ៗ

---

១ ចេតសិកពួកនេះ ក្នុងអភិធម្មត្ថសង្គហៈ បរិច្ឆេទចេតសិក ។

២- រាជគ្រូវិចារោ ជាអ្នកណែនាំព្រះរាជាឲ្យពិចារណានូវកិច្ចការផ្សេង ៗ

៣- រាជគ្រូអធិមោក្ខោ (១) ជាអ្នកណែនាំព្រះរាជាឲ្យមានព្រះទ័យតាំងស៊ប់ក្នុងកិច្ចការផ្សេង ៗ ។

ព្រះពាមចិត្តរាជ ព្រះអង្គមានឥសី ៣ រូបថ្វាយបង្គំរាយអភិញ្ញា និងសមាបត្តិ ព្រះអង្គទ្រង់តាំងទុកក្នុងឋានន្តរសក្តិជាអ្នកពន្យល់ព្រះអង្គ

១- ព្រះបីតិ (១) ជាអ្នកពន្យល់ព្រះរាជាឲ្យបានព្រះអំណររីករាយផ្ទាល់ត្រេកត្រអាលនឹងរាជការផ្សេង ៗ

២- ព្រះឆន្ទោ ជាអ្នកពន្យល់ព្រះរាជាឲ្យមានព្រះទ័យស្រឡាញ់នូវកិច្ចការទាំងពួង

៣- ព្រះវីរិយោ ជាអ្នកពន្យល់ព្រះរាជាឲ្យបានព្រះទ័យ

---

១ ចេតសិកពួកនេះ ក្នុងអភិធម្មសង្គហៈហៅថាបកិណ្ណកចេតសិក ។

ព្យាយាមក្នុងកិច្ចការផ្សេង ៗ ។

មិនតែប៉ុណ្ណោះ ព្រះបាទចិត្តរាជព្រះអង្គមានព្រះភិក្ខុ ៣ រូបទ្រង់តាំងទុកសមណសក្តិជាព្រះជីតុន សម្រាប់ជួយរំលឹកព្រះអង្គគឺ

១- ព្រះអនិច្ចំ ជាអ្នករំលឹកព្រះរាជាឱ្យនឹកឃើញសេចក្តីមិនទៀងរបស់សង្ខារ

២- ព្រះទុក្ខំ ជាអ្នករំលឹកព្រះរាជាឱ្យនឹកឃើញសេចក្តីទុក្ខរបស់សង្ខារ

៣- ព្រះអនត្តា ជាអ្នករំលឹកព្រះរាជាឱ្យនឹកឃើញសេចក្តីមិនមានខ្លឹមសាររបស់សង្ខារ ។

ព្រះជីតុនទាំង ៣ រូបនេះតែងរំលឹកធម៌អាថ៌ចំពោះព្រះមហាក្សត្រ ឱ្យទ្រង់ពិចារណាឃើញតាមពិតក្នុងព្រះត្រៃលក្ខណញ្ញាណ មិនឱ្យព្រះអង្គភ្លេចប្រហែសក្នុងកុសលករណីយ៍ទាំងឡាយ ។

ព្រះបាទចិត្តរាជ ព្រះអង្គមានព្រះញាតិវង្ស ១៨ អង្គ ជាព្រះញាតិខាងព្រះមាតា-បិតា ជាបាបជន មានយោបល់មិនប្រពៃ ព្រះអង្គតាំងទុកក្នុងឋានន្តរសក្តិទីយុទ្ធគ្រប់រូបគឺ :

១- ឃុនមោហោ(១) ជាអ្នកនាំព្រះរាជាឱ្យវង្វេង

២- ឃុនអហិរិកំ ជាអ្នកនាំព្រះរាជាមិនឱ្យខ្មាសបាប

៣- ឃុនអនោត្តប្បំ ជាអ្នកនាំព្រះរាជាមិនឱ្យខ្លាចបាប

៤- ឃុនឧទ្ធច្ចំ ជាអ្នកនាំព្រះរាជាឱ្យរាយមាយ

៥- ឃុនលោភោ ជាអ្នកនាំព្រះរាជាឱ្យលោភ

៦- ឃុនទិដ្ឋិ ជាអ្នកនាំព្រះរាជាឱ្យយល់ខុស

៧- ឃុនមានោ ជាអ្នកនាំព្រះរាជាឱ្យប្រកាន់ព្រះអង្គ

៨- ឃុនទោសោ ជាអ្នកនាំព្រះរាជាឱ្យប្រទូស្តគេ

៩- ឃុនឥស្សា ជាអ្នកនាំព្រះរាជាឱ្យច្រណែនគេ

១០- ឃុនមច្ឆរិយំ ជាអ្នកនាំព្រះរាជាឱ្យកំណាញ់

១១- ឃុនកុក្កុច្ចំ ជាអ្នកនាំព្រះរាជាឱ្យអន្ទះអន្ទែង.

១២- ឃុនថីនំ ជាអ្នកនាំព្រះរាជាឱ្យរួញរា

១៣- ឃុនមិទ្ធំ ជាអ្នកនាំព្រះរាជាឱ្យងុយងោក

១៤. ឃុនវិចិកិច្ឆា ជាអ្នកនាំព្រះរាជាឱ្យសង្ស័យ

---

(១) [illegible]ពាក្យទាំង ១៤ នេះក្នុងអភិធម្មត្ថសង្គហៈហៅថា[illegible]
[illegible]ចេតសិក

WAT KHEMARARATANARAM

ព្រះញាតិវង្សទាំង ១៤ អង្គនេះ។ ជាអ្នកទុកព្រះទ័យ ព្រះពុទ្ធចិត្តរាជយ៉ាងជិតស្និទ្ធ ព្រះអង្គតែងប្រោសប្រាណឱ្យចូល ជិតគាល់បម្រើជានិច្ចកាល ពុំដែលខានពេលណាមួយឡើយ ។

ព្រះរាជាចិត្តរាជ ព្រះអង្គមានអគ្គសេនា ១៩ នាក់ ជាវរជនមានយោបល់ល្អ ព្រះអង្គតាំងទុកក្នុងឋានន្តរសក្តិ ទី ឧកញ៉ាគ្រប់រូបគឺ

១- ឧកញ៉ាសទ្ធា(១) ជាអ្នកនាំព្រះរាជាឱ្យជឿកម្មផល

២- ឧកញ៉ាសតិ ជាអ្នកនាំព្រះរាជាឱ្យមានព្រះស្មារតី,

៣- ឧកញ៉ាហិរិ ជាអ្នកនាំព្រះរាជាឱ្យខ្មាសបាប .

៤- ឧកញ៉ាឱត្តប្បំ ជាអ្នកនាំព្រះរាជាមិនឱ្យខ្លាចបាប,

៥- ឧកញ៉ាអលោភោ ជាអ្នកនាំព្រះរាជាមិនឱ្យលោភ,

៦- ឧកញ៉ាអទោសោ ជាអ្នកនាំព្រះរាជាមិនឱ្យប្រទូស្តគេ,

---

១ ចេតសិកទាំង ១៩ នេះក្នុងអភិធម្មត្ថសង្គហៈហៅថា សោភណសាធារណចេតសិក ។

៧_ ឧកញ៉ាតត្រមជ្ឈត្តតា ជាអ្នកនាំព្រះរាជាឲ្យបាន ព្រះទ័យជាកណ្តាល .

៨_ ឧកញ៉ាកាយបស្សទ្ធិ ជាអ្នកនាំព្រះរាជាឲ្យបាន ព្រះធាមកាយរម្ងាប់

៩_ ឧកញ៉ាចិត្តបស្សទ្ធិ ជាអ្នកនាំព្រះរាជាឲ្យបាន ព្រះទ័យរម្ងាប់

១០_ ឧកញ៉ាកាយលហុតា ជាអ្នកនាំព្រះរាជាឲ្យ បានព្រះធាមកាយស្រាល

១១_ ឧកញ៉ាកាយមុទិតា ជាអ្នកនាំព្រះរាជាឲ្យ បានព្រះធាមកាយទន់ភ្លន់

១២_ ឧកញ៉ាចិត្តមុទិតា ជាអ្នកនាំព្រះរាជាឲ្យ បានព្រះទ័យទន់ភ្លន់

១៣_ ឧកញ៉ាកាយកម្មញ្ញតា ជាអ្នកនាំព្រះរាជាឲ្យ បានព្រះធាមកាយគួរបល់ការងារ

១៤_ ឧកញ៉ាចិត្តកម្មញ្ញតា ជាអ្នកនាំព្រះរាជាឲ្យ បានព្រះទ័យគួរបល់ការងារ

១៦_ ឧកញ៉ាកាយបាគុញ្ញតា ជាអ្នកនាំព្រះរាជាឲ្យបានព្រះនាមកាយជំនាញ

១៧_ ឧកញ៉ាចិត្តបាគុញ្ញតា ជាអ្នកនាំព្រះរាជាឲ្យបានព្រះទ័យជំនាញ

១៨_ ឧកញ៉ាកាយុជុកតា ជាអ្នកនាំព្រះរាជាឲ្យបានព្រះនាមកាយត្រង់

១៩_ ឧកញ៉ាចិត្តុជុកតា ជាអ្នកនាំព្រះរាជាឲ្យបានព្រះទ័យត្រង់ ។

អគ្គសេនាទាំង ១៩ នាក់នេះ ជាទីពុកព្រះទ័យព្រះរាជាចិត្តរាជ ព្រះអង្គទ្រង់តាំងទុកជាគណបក្សប្រឹក្សា សម្រាប់ជំនុំការរាជការ ដែលកើតក្នុងដែនដីនៃនគរកាយ តាមព្រះនេត្រ ព្រះកាណ៌ព្រះអង្គ ។

ព្រះរាជាចិត្តរាជ ព្រះអង្គគ្រប់គ្រងរាជសម្បត្តិជាសម្បូរណ៍ ជាសិទ្ធិរាជ បានព្រះរាជអំណាចពេញសម្បូណ៌ បរិបាលសុខសប្បាយក្នុងកាយប្រទេស ល្បីឮសុសសាយពូទៅដល់ប្រទេសនានា ។

# ឯកោ រាជា មច្ចុ នាម មហិទ្ធិកោ អហោសិ

សាធុសប្បុរសទាំងឡាយ !

ក្នុងទីមិនឆ្ងាយពីនគរកាយនោះ មានព្រះរាជាមួយព្រះអង្គទៀត ព្រះនាមព្រះពាច **មច្ចុរាជ** ជាព្រះរាជាដ៏មានមហិទ្ធិរិទ្ធិ មានសន្ធានអាក្រក់ តែងត្រាច់ទៅគ្រប់សង្កត់សព្វសត្វក្នុងត្រៃភព តាំងពីមនុស្សលោករហូតព្រហ្មលោក ឲ្យឋិតនៅក្នុងកណ្តាប់ព្រះហស្តនៃព្រះអង្គ . ស្តេចមានចតុរង្គសេនា ៤ កងពលធំ សុទ្ធតែជាមេទ័ពដ៏មានប្រតិពលក្នុងកលោបាយនិងយុទ្ធពិធីគ្រប់ចំពូក មានឥទ្ធិរិទ្ធិ៍ចេស្តាមហិមាអាចផ្ចាញ់បច្ចាមិត្តគ្រប់ទិសទិសឲ្យបរាជ័យ ឥតមិនមាននរណាមួយក្នុងត្រៃលោកគេចផុតបានឡើយ ។

ចតុរង្គសេនា ៤ កងពលធំនោះ មានមេទ័ព ៤ នាក់គឺ

១_ **នាយជាតិ** ជាមេទ័ពមានសមត្ថភាពខាងស្ថាបនាវត្ថុធាតុផ្សេង ៗ ដែលមិនទាន់កើត ឲ្យកើតឡើង

២_ **នាយជរា** ជាមេទ័ពមានសមត្ថភាពខាងធ្វើវត្ថុធាតុផ្សេង ៗ ដែលខាំងបង្កើតឡើងហើយ ឲ្យទ្រុឌទ្រោមទៅ

៣- ឆាយព្យាធិ ជាមេទ័ពមានសមត្ថភាពខាងធ្វើឲ្យរាំងមែលមានកំលាំងរឹងប៉ឹង ឲ្យទុព្វលភាព ។

៤- ឆាយមរណៈ ជាមេទ័ពមានសមត្ថភាពខាងសម្លាប់ឆ្មាំងគេចរួចម្នាក់ ។

មេទ័ពម្នាក់ ៗ មានបរិវារច្រើន តែងចេញចូលគាល់បម្រើរក្សាការពារព្រះអង្គព្រះបាទមច្ចុរាជជានិច្ចកាល. ព្រះបាទមច្ចុរាជតែងទ្រង់ ប្រើទៅសម្លាប់ពួកខ្មាំងទាំងពួងក្នុងត្រៃលោក ។

កិត្តិស័ព្ទព្រះបាទចិត្តរាជ បានល្បីរន្ទឺឮសាយទៅដល់ព្រះបាទមច្ចុរាជនោះថា មាននគរ ១ ឈ្មោះនគរកាយ ជាស្រុកនិទុក្ខ សុខសប្បាយក្រៃពេក. ព្រះរាជា ជាអធិប្រមុខនគរកាយនោះ ព្រះនាមព្រះចាំចិត្តរាជ ជាបរមក្សត្រគ្រងសិរីសម្បត្តិសម្បូរណ៍ដោយព្រះរាជអំណាចមហិមា ។

កាលបំណើននោះ ឮសាយទៅដល់ព្រះសោតនៃព្រះបាទមច្ចុរាជ ៗ ក៏ទ្រង់រិតក្តុយរ៉ាំងក្រៃលែង ខ្លាចក្រែងព្រះបាទចិត្តរាជកន្លងវិស័យនៃព្រះអង្គ ទ្រង់មានព្រះរាជបំណងនឹងប្រើមេទ័ព

ទាំង ៤ កងឱ្យទៅវាយបណ្ដើមយកនគរតាំងនោះ ឱ្យនៅក្រោមអំណាចព្រះអង្គមួយរំពេច. តែស្ដេចទ្រង់ព្រះតម្រិះឃើញថា " ព្រះចៅចិត្តរាជ ជាមហាក្សត្រដ៏មានអានុភាពមហិមា មានសេនាទាហានគ្នាហ៊ានសព្វមុខមន្ត្រី គុះករបរិបូណ៌ក្រៃពេក. បើអាត្មាអញលើកកងទ័ពទៅកាប់យកភ្លាម ៗ ឃើញជាពុំងាយបានឡើយ. ណ្ហើយកុំម្លោះ ចាំអាត្មាអញប្រើចារទាហានទៅលបលួងយកដោយកលោបាយវិញ គឺអាត្មាអញត្រូវបញ្ជូនបេចំព ដ៏មានសមត្ថភាព ឱ្យទៅក្លែងធ្វើជាខ្ញុំបំរើផ្ទាល់ព្រះចៅចិត្តរាជជាមុនសិន កាលបើចារទាហានអាត្មាអញទៅប្រតិបត្តិការបានសម្រេចហើយ សឹមអាត្មាអញឱ្យលើកកងទ័ពទៅវាយយកជាក្រោយ. បើធ្វើដូច្នេះប្រហែលជាបានងាយ " ។

កាលព្រះចៅបថុរាជទ្រង់ព្រះតម្រិះឃើញឧបាយដូច្នេះ ក៏ទ្រង់ព្រះបញ្ជាឱ្យហៅមេទ័ពទី ១ ឈ្មោះនាយជាតិចូលមកភ្លាម ។

លុះនាយជាតិចូលមកគាល់. ស្ដេចទ្រង់ត្រាស់ថា :

" នែនាយជាតិ ! ចូរចៅចូលយកអាសារយើងក្នុងគ្រាឥឡូវនេះ. ចូរឯងទៅកាន់នគរកាយជាប្រញាប់ . កាលទៅ

បល់ ចូរចៅឯងទៅអែបអបធ្វើខ្លួនឲ្យជាទីជឿជាក់ស្និទ្ធស្នាលជាមួយនឹងសេវកាមាត្យ ព្រមទាំងមាតាបិតាវង្សាគណាញាតិនៃព្រះចៅចិត្តរាជ. បើចៅឯងបានជាទីស្និទ្ធស្នាលនឹងគេហើយ ចូរចៅឯងចូលថ្វាយខ្លួនជាខ្ញុំគាល់បម្រើគេជានិច្ច នឹងខំធ្វើរាជការគេឲ្យល្អ ឲ្យគេទុកចិត្តរាប់អានស្រឡាញ់ចៅ ដើម្បីនឹងបានជាសេយ្យសឹកក្នុងស្រុកគេ. កាលធ្វើការបានសម្រេចហើយ ចូរចៅឯងធ្វើដំណឹងមកយើង ។

លុះត្រាស់ដូច្នោះ ក៏ទ្រង់បញ្ជូននាយជាតិឲ្យទៅកាន់នគរកាយ ឯនាយជាតិកាលបានទទួលព្រះរាជឱង្ការហើយ ក៏នាំបរិវារធ្វើដំណើរឆ្ពោះទៅកាន់នគរកាយនោះតាមព្រះរាជបញ្ជា

លុះនាយជាតិបានទៅដល់កាលណា ក៏ចូលទៅធ្វើជាមិត្តស្និទ្ធស្នាល ជាមួយនឹងនាហ្មឺនសព្វមុខមន្ត្រី ដោយសេចក្តីឆ្លៀវឆ្លាសរបស់ខ្លួន ហើយក៏ចូលទៅថ្វាយខ្លួនព្រះមាតា - បិតា អគ្គមហេសី នឹងព្រះញាតិវង្ស នៃព្រះចៅចិត្តរាជ. កាលឃើញថា វរជនទាំងនោះ គេស្រឡាញ់ពេញចិត្តអាណិតអាសូរខ្លួនហើយ ក៏ឲ្យគេនាំខ្លួនទៅថ្វាយព្រះមហាក្សត្រ ។ វរជនទាំងនោះ ក៏នាំនាយជាតិទៅ សុំឲ្យតែងបុណ្យសក្តិក៏ទ

ដោយរវៀងតាមព្រះនាងអរិដ្ឋទេវី ជាព្រះអគ្គមហេសី ពុំមានឱកាសចេញទៅទតព្រះធតរកាយបានឡើយ ។

ព្រះអធិប្ដី ជាព្រះជីតុន កាលបានឃើញព្រះបាទចិត្ររាជនៅព្រងើយព្រងោះ ទើបចូលទៅថ្វាយព្រះពរតៀនថ្លងទៀតថា :

“ បពិត្រមហារាជ ថ្វីទ្រង់ធ្វើព្រះការុញ្ញភាព !

ហេតុម្ដេចបានជាព្រះអង្គគង់ស្ងៀមម្ល៉េះ ? មិនសមគួរទេព្រះអង្គ ! ឥឡូវព្រះធតរកាយរបស់ព្រះអង្គត្រាំត្រាហើយ សូមស្ដេចយាងទៅទតខ្លះផង ។

លុះព្រះជីតុនប្រាសតៀនបល់ពីរបង. ព្រះបាទចិត្ររាជទ្រាំគង់ស្ងៀមពុំបាន ក៏ទ្រង់ស្ដេចទៅទតបន្ដិច ឃើញដូចពាក្យព្រះជីតុនរំលឹកមែន. តែគង់នៅស្ងៀមទៅវិញ ពុំបានគិតបល់ព្រះធតរឡើយ ។ ទោសទាំងនេះមកតែពីទ្រង់រវៀងដោយព្រះនាងអរិដ្ឋទេវី ។

កាលនាយជាតិ និងជរា ជាមេទ័ពទាំង ២ នាក់ ឃើញអាការដូច្នោះ ក៏បញ្ជូនសារទៅថ្វាយ ព្រះបាទមធុរាជថា :

សូមព្រះតេជៈបរិគល់លើត្បូង
សូមព្រះរាជទានក្រាបបង្គំទូលព្រះករុណាជា
អម្ចាស់ជីវិត
សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។
សូមទ្រង់មេត្តាប្រោស !

ឥឡូវព្រះបាទមិត្តរាជកំពុងប្រមាថ. សូមទ្រង់បញ្ជូនទ័ពទី ៣ ព្រមទាំងយោធាជាបរិវារទៅទៀត ដើម្បីប្រតិបត្តិការឱ្យឆាប់បានសម្រេចទាន់ព្រះរាជហឫទ័យតទៅ ។

ហត្ថលេខា នាយជាតិ . ជរា

លុះព្រះបាទបទុមរាជ បានទ្រង់ជ្រាបព្រឹត្តិការណ៍នោះ ទើបទ្រង់ព្រះរាជបញ្ជាប្រើនាយព្យាធិជាមេទ័ពកំណាចទី ៣ ព្រមទាំងបរិវារ ៩៦ នាក់ គឺចត្តុរតិរោគឱ្យមកកាន់នគរកាយ ។ នាយព្យាធិព្រមទាំងបរិវារក៏នាំគ្នាទៅតាមព្រះរាជបញ្ជា . កាលទៅដល់ហើយនាយព្យាធិព្រមទាំងបរិវារ ៩៦ នាក់ បានញាំញីកំទេចទ្វារនគរនិងបន្ទាយតូចធំ ព្រមទាំងគ្រឿងប្រដាប់ផ្សេង ៗ ឱ្យរលំរលាយបាក់បែកគ្រប់អន្លើ . អ្នកនគរកើត

បលាបលរកចេញចូលពុំបានៈ ។ ក្រោយនេះ ដោយព្រាហ្មាតែ ច្បាប់យកព្រះបាទចិត្តរាជបួយមុខបំណ្ឌារ ។

ឯព្រះពុទ្ធ ជាព្រះអ៊ីតុន កាលបានឃើញក៏ចូលទៅថ្វាយ ព្រះពរព្រះបាទចិត្តរាជថា :

" បពិត្រមហារាជ ដ៏ទ្រង់គួរព្រះតេជានុភាព !

ព្រះអង្គមិនទាន់ជ្រាបទេឬ ? ឥឡូវព្រះធនករកាយនៃ ព្រះអង្គវិកលវិការហើយ ដោយធាយជាតិជាលេខទីពី ១ ដែល ចូលមកនៅមុនបង្អស់គេគប់គិតគំនិតជាមួយ ធាយជរាលេខទីពី ២ និង ធាយព្យាធិលេខទីពី ៣ ព្រមទាំងពន្ធរុតិរ៉ាត ៩៦ នាក់ជាបរិវារនាំគ្នាធ្វើឱ្យវិករ. បើព្រះអង្គធ្វើព្រងើយកន្តើយ ព្រះធនករកាយមុខជាអន្តរាយពុំខានស្លូប់ទ្រង់ជ្រាប " ។

ព្រះបាទចិត្តរាជបរមបព្ត្រ កាលបានទ្រង់ព្រះសណ្តាប់ ឮដូច្នោះក៏រសាប់រសល់ក្នុងព្រះទ័យក្រៃពេក ទ្រង់ស្តេចចេញទៅ ទតសព្វសព៌ាង្គព្រះធនករកាយ. លុះឃើញច្បាស់ក៏ទ្រង់សោយទុក្ខ វេទនាទ្រង់ព្រះកន្សែងខ្សឹកខ្សួលជាខ្លាំង រកបុគ្គលណាមួយជួយ យកអាសាក៏បាត់ព្យាធិសេនាជាខ្លាំងស្រុតរពុំបាន ដោយ

មហាជនទាំងពួងសឹងតែខ្លាចអំណាចព្យាធិសេនាទាំងអស់គ្នា ។

លុះនាយជាតិ - ជរា - ព្យាធិ ជាមេទ័ពទាំង ៣ នាក់ បានឃើញអាការដូច្នេះ ក៏បញ្ជូនសារទៅថ្វាយព្រះបាទ មច្ចុរាជថា :

សូមព្រះតេជៈបំកល់លើត្បូង
សូមព្រះរាជទានក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិត
សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។
សូមទ្រង់ព្រះមេត្តាប្រោស !
ឥឡូវនេះ ព្រះបាទចិត្តរាជខ្សោយកម្លាំងណាស់ហើយ
សូមទ្រង់បញ្ជូនមេទ័ពទី ៤ ទៅទៀតជាប្រញាប់ ដើម្បី
ព្រួតគ្នាចាប់តួព្រះបាទចិត្តរាជយកមកថ្វាយយ៉ាងរួសរាន់ ។

ហត្ថលេខា នាយជាតិ. ជរា. ព្យាធិ

កាលព្រះបាទមច្ចុរាជបានទ្រង់ជ្រាប ប្រព្រឹត្តិហេតុនោះ ក៏ទ្រង់ បញ្ជូនមេទ័ពទី ៤ ធំបំផុតឈ្មោះនាយមរណៈ ដ៏មានអនុភាពមហិមា ជាងមេទ័ពមុន ៗ អាចប្រាបប្រាប

បផ្លាញព្រាត់ព្រាយទិសតំបន់ ឱ្យវិនាសអន្តរាយកណ្តាលសមរភូមិ ។ សត្តិករ ក្នុងព្រៃលៀកសឹងកោតខ្លាចអំណាចមេទ័ពនេះណាស់ ក្រាត់តែឮឈ្មោះថា មរណៈសេនាបតិតផល់ក៏សឹងតែនាំគ្នារត់ជ្រកយកតែអាយុរៀងខ្លួន. តែទោះបីរកណារត់ទៅឮគន្លងទីណា ៗ ក្តី ក៏ពុំរួចពីកណ្តាប់ដៃនាយមរណៈនោះបានឡើយ ។

ឯមេទ័ពទី ៤ ឈ្មោះនាយមរណៈកាលបានទទួលព្រះរាជបញ្ជាហើយ ក៏នាំបរិវារទៅកាត់ធតរកាយ លុះចូលទៅដល់ទៅសព្វញាតិនមេទ័ពទាំង ៣ នាក់ដែលមកមុននោះ ហើយក៏រុករានចន្ទ្រានបុកដៃធញ្ញាញីបិទទ្វារទាំង ៩. ដែលធតរកាយឱ្យងងឹតជុំវិញ ហើយចូលទៅនៃញចាប់ក្នុងអង្គ ព្រះពាទចិត្តរាជបានព្រមទាំងនាហ្លួនសព្វមុខមន្ត្រី និងអាណាប្រជាជនទាំងពួងគ្នានសល់ម្នាក់ នាំចេញចាកធតរកាយ ។

ឯធតរកាយនោះ កាលបើពុំមានបុគ្គលណាមួយនៅហើយក៏ត្រូវព្រោះទៅ ។

ធតរកាយ គឺរាងកាយយើង គេទាំងពួង. ព្រះបាទ

ចិត្តរាជ គឺចិត្តយើងគេទាំងពួង គឺមិត្តតែចិត្តពុំឋិតនៅក្នុង រាងកាយហើយ . រាងកាយក៏ពុំអាចចប់ចល់នៅបាន តែបរល់ ផុតសភាពថារាងកាយស្អុយរលួយជាធម្មតា ដោយប្រការ ដូច្នេះ ។

សាធុសប្បុរសទាំងឡាយ !

កាលមេទ័ពទាំង ៤ នាក់ ព្រមទាំងបរិវារ ចាប់ព្រះបាទចិត្តរាជបានហើយ ក៏នាំទៅកាន់សំណាក់ព្រះបាទបទុមរាជ ។ ឯព្រះបាទបទុមរាជកាលឱ្យចាប់ព្រះបាទចិត្តរាជបានមកហើយ នឹងយកទុកនៅជាខ្ញុំបម្រើក៏ទេ.' ត្រឡប់ជាបណ្តេញទៅវិញថា " ចូរអ្នកឯងទៅតាមយថាភព្វខ្លួនចុះ ! ។

លំដាប់ពីនោះ ព្រះបាទចិត្តរាជក៏នាំបរិពារទៅរកទីលំនៅកសាងនគរកាយជាថ្មីដូចមុន ។

ឯព្រះបាទបទុមរាជជាស្តេចកំពប់ កាលបានជ្រាបថា ព្រ.បាទចិត្តរាជកសាងនគរកាយជាថ្មី ក៏ទ្រង់ប្រើមេទ័ពទាំង ៤ ឱ្យទៅតាមបៀតបៀនចាប់ចូលអង្គព្រះបាទចិត្តរាជ ឱ្យព្រាត់ចាក

នគរកាយជាថ្មីនោះទៀត និមិត្តពៃព្រះបាទចិត្តរាជកសាងនគរកាយវេលាណា ក៏ធ្វើឱ្យអន្តរាយវេលានោះរាល់គ្រា ពុំដែលខានម្ដងណាឡើយ ។

ព្រះបាទចិត្តរាជ ក៏ទ្រង់សោយទុក្ខវេទនាក្ដានស្រោកស្រាន្ត ។

គ្រាមួយ ជាវេលាមានជោគវាសនាល្អ . ព្រះបាទចិត្តរាជក៏ទ្រង់ព្រះតម្រិះថា " អាត្មាអញធ្វើម្ដេចនឹងបានរួចពីកណ្ដាប់ដៃនៃមច្ចុរាជនេះបានអេះ ? ឱហ្ន៎ ! អាត្មាអញនឹងឱ្យទៅអារាធនាព្រះភិក្ខុជាព្រះជីតុន នឹងឥសីចូលមកប្រឹក្សាថា ក្រែងលោកឃើញឧបាយយ៉ាងណាខ្លះ ? " ។ លុះទ្រង់ព្រះ តម្រិះហើយក៏ទ្រង់ព្រះបញ្ជាប្រើមហាតលិក ២ នាក់គឺ ហ្លួនចេតនាជាមហាតលិកស្ដាំ. ហ្លួនមនសិការោ ជាមហាតលិកឆ្វេងថា :

" នែពាទាំងឡាយ ! ចូរពាយកអាសាយើងទៅអារាធនាព្រះភិក្ខុជាព្រះជីតុនទាំង ៣ រូបគឺព្រះអនិច្ចំ_ទុក្ខំ_អនត្តា នឹងព្រះឥសីទាំង ៣ រូបគឺ ព្រះបីតិ _ ឆន្ទោ _ វីរិយោ នូវបុរោហិតទាំង ៣ រូបគឺ ព្រះរាជគ្រូវិតក្កោ_វិចារោ អធិមោក្ខោហើយនិងអន្តសេនាទាំង ១៩ នាក់មានឧកញ៉ាសទ្ធាជាដើម

ឱ្យមកកាន់សំណាក់យើងក្នុងខណៈនេះ ” ។

មហាឥស្សីទាំងពីរនាក់ ក៏ម្នីម្នាទៅរកវរស្រមណ៍និង វរជនទាំងនោះតាមព្រះរាជបញ្ជា ។ វរស្រមណ៍ និងវរជនទាំងនោះ ក៏នាំគ្នាទៅកាន់ព្រះរាជសំណាក់តាមសេចក្ដីអារាធនា_អញ្ជើញ. លុះទៅដល់ក៏ព្រះបាទចិត្តរាជត្រាស់ប្រឹក្សាការផែនដីថា :

“ បពិត្រលោកអ្នកនិងពួកទាំងឡាយ !

ខ្ញុំសូមប្រឹក្សា និងលោក សូមលោករកឧបាយ ដើម្បីឱ្យខ្ញុំរួចចាកកណ្ដាប់ដៃនៃមច្ចុរាជ ” ។

ព្រះពីពុធ ព្រមទាំងវរជនទាំងពួងដែលបានជួបជុំក្នុងមហាសន្និបាតនោះ ថ្វាយព្រះពរឡើងព្រមគ្នាថា :

“ បពិត្រព្រះសម្មតិទេវរាជ !

ការប្រឹក្សាគ្រានេះជាការធំបុំណាស់ . ការនេះដែលនឹងសម្រេចដាច់ខាតទៅបាន លុះតែបានសម្ដេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គ គឺព្រះសមាធិន្ទ្រិយ និងព្រះបញ្ញិន្ទ្រិយ មកជាទីប្រឹក្សាផង. សូមព្រះអង្គឱ្យទៅអារាធនាសម្ដេចមក ” ។

ព្រះពាចមិត្តរាជបានទ្រង់ព្រះសណ្ដាប់ទីប្រជុំ ក៏ទ្រង់ត្រាស់ប្រើហ៊ឹងឯកត្តតា ជាមហាតល្លិកហើយបានចិត្តស្និទ្ធស្រឡាញ់ថា ៖

“ នែហ៊ឹងឯកត្តតា ! ចូរទៅអារាធនាសម្តេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គមកជាប្រញាប់ ” ។

ហ៊ឹងឯកត្តតា ក៏នាំព្រះរាជឱង្ការទៅថ្វាយបង្គំទូលសម្តេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គថា ៖

“ បពិត្រសម្តេចដ៏ទ្រង់នូវសីលធិបរិសុទ្ធ !

ព្រះពាចមិត្តរាជ ត្រាស់ប្រើទូលព្រះបង្គំ ជាខ្ញុំឱ្យមកអារាធនាសម្តេចទាំង ២ ព្រះអង្គចូលទៅកាន់ព្រះនិវេសន៍ក្នុងខណៈនេះ ” ។

សម្តេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គ កាលបានចូលនិមន្តហើយ ក៏ទ្រង់ស្លៀកស្បង់ព្រមចីវរស្ពាយបាត្រ ទ្រង់យាត្រាទៅតាមមាគ៌ាទាំង ៤ ជាលោកុត្តរមាគ៌ា តាមលំដាប់ គឺ សោតៈ សកទាគា អនាគា អរហត្ត ដែលជាមាគ៌ាអាចនាំព្រះពាចមិត្តរាជ ៖ ចេញផុតពីកណ្តាប់ដៃនៃមច្ចុរាជអោយស្លុះស្លី បាន ។

លុះសម្តេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គនិមន្តដោយ

ផ្ទុំវង់ ចូលទៅកាន់ព្រះរាជសំណាក់ គង់លើអាសនៈដ៏សមគួរ ហើយ ព្រះពាលចិត្តរាជក៏ធ្វើសក្ការបូជាគោរពហើយត្រាស់ពិត ថេរបីកាថា :

" បពិត្រសម្ដេចទាំង ២ ព្រះអង្គ !

ខ្ញុំបានសេចក្ដីអផ្សុកខ្លាំងណាស់ បានជាឱ្យអារាធនា សម្ដេចជាអម្ចាស់មក ដើម្បីទ្រង់ជួយដោះទុក្ខខ្ញុំក្នុងគ្រា ឥឡូវនេះ ព្រោះមច្ចុរាជនេះតែងមកបៀតបៀនខ្ញុំ ដោយគេ ប្រើមេទ័ពទាំង ៤ ព្រមទាំងបរិវារឱ្យមកធ្វើបាបខ្ញុំ គ្រប់ ពេលដែលខ្ញុំសាងធតរកាយ ពុំដែលខានពេលណា ព្រោះថាឱ្យ ខ្ញុំនៅក្នុងអំណាចគេ . បពិត្រសម្ដេចដ៏ចម្រើន ! ធ្វើ ដូចម្ដេចហ្ន៎ ឱ្យខ្ញុំបានរួចរំពីកណ្ដាប់ដៃសត្រូវនេះបាន ? " ។

សម្ដេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គ គឺព្រះ សមាធិន្ទ្រិយ និងព្រះបញ្ញិន្ទ្រិយ លុះបានស្ដាប់ព្រះរាជឱង្ការ ហើយ ក៏ប្រឹក្សាជាមួយនឹង ព្រះពីពុធទាំង ៣ រូប គឺ ព្រះអនិច្ចំ-ទុក្ខំ-អនត្តា និងព្រះឥសីទាំង ៣ រូប គឺ ព្រះ បីតិ-ឆន្ទោ-វីរិយោ ។

ខែសេចក្ដីថា កាលសមាធិ និងបញ្ញាកើតឡើងក្នុងចិត្ត

ទើបពិតឃើញព្រះត្រៃលក្ខណ៍ . កាលព្រះត្រៃលក្ខណញ្ញាណ កើតមានឡើង តែងមានបីតិ ( អំណរ ) ផ្លូតផ្ដាច់បង្ហូរទៅក្នុង អកុសលធម៌ទាំងពួង . មានឆន្ទៈ ( ស្រឡាញ់ ) កុសល កាត់អកុសលចោលបង់មិនត្រេកអរ និងមានវីរិយៈ ( ព្យាយាម ) ប្រាថ្នាឱ្យផុតចាកសង្សារវដ្ដ ។

សម្ដេចព្រះមហាសង្ឃរាជក៏ប្រឹក្សានឹងបុរោហិត ៣ រូប គឺរាជគ្រូពិតក្កោ_វិចារោ_អធិមោក្ខោតទៅទៀតថា " លោកណាយល់យ៉ាងណាខ្លះ ? " ។ រាជគ្រូទាំង ៣ រូប នឹករំពឹងទៅក៏ឃើញទោសរបស់បុគ្គលជាពួកអកុសល ហើយពិតថេរវីកាថា " ទូលព្រះបង្គំជាខ្ញុំទាំងឡាយយល់តាមសម្ដេចទាំងអស់ " ។

កាលបើដូច្នោះ សម្ដេចមហាព្រះសង្ឃរាជទាំង ២ ព្រះអង្គ ក៏ប្រឹក្សាសួរទៅឧកញ៉ា ពញា ព្រះ ហ្លួង ឃុន ហ៊ិន និង មហាតឡឹកទាំងពួង មានឧកញ៉ាសង្ខាជាដើមថា " លោកអ្នកទាំងអស់នេះ យល់ឃើញដូចម្ដេច ? " ។

វរជនទាំងនោះកាលប្រឹក្សាឈប់គ្នាត្រូវ ក៏ពិតថេរវីកាថា

ទោសទាំងនេះ មានតែពីពាបជនទាំង ១៤ ព្រះអង្គ

មានឈ្មោះមោហោជាដើមជាព្រះញាតិវង្ស . ព្រះបាទមោហោរាជ ជាព្រះបិតា . ព្រះនាងលោភទេវីជាព្រះមាតា និងព្រះនាងអរតិទេវីជាព្រះអគ្គមហេសី បានស្ម័គ្រយកមេទ័ពទាំង ៤ នាក់ របស់មច្ចុរាជ មាននាយជាតិជាដើមឱ្យមកនៅក្នុងព្រះនគរកាយ បានជាគេនាំគ្នាធ្វើព្រះនគរនេះឱ្យអន្តរាយអស់ ។

កាលទីប្រឹក្សាបានពិភាក្សាអស់កាលយូរ យល់ឃើញព្រមគ្នាហើយ ទើបយកសេចក្ដីក្រាបបង្គំទូលព្រះបាទចិត្តរាជថា :

បពិត្រមហារាជ ដ៏ទ្រង់ធ្ងន់ព្រះរាជសម្ភារៈ !

ហេតុដែលនាំឱ្យខូចព្រះនគរកាយនេះ ទីប្រឹក្សាបានប្រឹក្សាឃើញមូលហេតុគ្នាហើយថា មកពីព្រះអង្គទ្រង់ជឿពាក្យពួកពាលជនទាំង ១៤ អង្គ មានឈ្មោះមោហោជាដើម ជាព្រះញាតិព្រះអង្គ .ជាសត្រូវក្នុងនាំសត្រូវក្រៅមកនៅក្នុងព្រះនគរ បានជាព្រះនគរកើតអន្តរាយបច្ចេះមួយទៀត មកពីព្រះបាទមោហោរាជជាព្រះបិតា ព្រះនាងលោភទេវីជាព្រះមាតា និងព្រះនាងអរតិទេវីជាព្រះអគ្គមហេសី ដែលព្រះអង្គបានព្រមព្រៀងជាមួយនិងព្រះញាតិទាំង ១៤ អង្គពួកពាលយកមេទ័ពព្រះបាទមច្ចុរាជទុក

្នុងព្រះនគរ ទើបពួកបច្ចាមិត្រគេនាំគ្នាធ្វើព្រះនគរកាយរបស់ព្រះអង្គឱ្យអន្តរាយម្តេះ . រឿងនេះបើព្រះអង្គជឿស្តាប់យើងទាំងឡាយជាទីប្រឹក្សា សូមព្រះអង្គកំចាត់បង់ព្រះញាតិវង្សទាំង ១៤ អង្គ ព្រះមាតា_បិតា និងព្រះអគ្គមហេសីចេញ. ទើបបច្ចាមិត្រលែងកើតទៀតបាន . ហើយយើងទាំងពួងនឹងនាំព្រះអង្គទៅកាន់នគរកែវជាអមតមហានគរ ជាទីបរមសុខព្រោសបាកទុក្ខផុតពីកណ្តាប់ដៃ នៃមច្ចុរាជ តាមព្រះរាជបំណងបាន ។

កាលព្រះពាមចិត្តរាជបរមក្សត្របានទ្រង់ព្រះសណ្តាប់ហើយ . ដោយទ្រង់មានព្រះរាជបំណងចង់រួចពីកណ្តាប់ដៃនៃមច្ចុរាជ ទ្រង់ក៏ធ្វើតាមពាក្យទីប្រឹក្សាទាំងពួង មានសម្តេចព្រះមហាសង្ឃរាជជាដើម ទើបទ្រង់តាំងមហាតឡិកម្នាក់ឈ្មោះហ៊ីនឯកត្តតា និងអគ្គសេនាម្នាក់ឈ្មោះឧកញ៉ាចិត្តជុកតា ដែលមានចិត្តស្មោះត្រង់នឹងព្រះអង្គ ឱ្យជាចៅក្រមជំនុំជំរះរឿងព្រះញាតិទាំងពួង ១៤ អង្គនូវព្រះមាតា_បិតា និងព្រះអគ្គមហេសីព្រមគ្នាចោទចំពោះព្រះភក្ត្រព្រះអង្គ ។

ក្នុងសេចក្តីជំនុំជំរះ ចៅក្រមសួរថា :

នែព្រះបាទមោហរាជ ! ព្រះនាងលោភទេវី ! ព្រះនាងអវិជ្ជាទេវី ! លោកទាំងអស់អង្គសុទ្ធតែជាព្រះមាតាបិតា អគ្គមហេសីនៃព្រះរាជា ទាំងមុន ១៤ អង្គក៏សុទ្ធតែជាព្រះញាតិព្រះរាជាទាំងអស់ ព្រះរាជាទ្រង់ព្រេសព្រាណទាំងអស់លោកនាហ៊ីនគ្រប់គ្នា . ហេតុដូចម្តេចបានជាអស់លោកមិនពិគ្រោះព្រះអង្គដោយយុត្តិធម៌ បែរជាទៅក្រាបទូលណែនាំការមិនជាប្រយោជន៍ដល់ព្រះអង្គវិញ គឺនាំយកសត្រូវពីក្រៅឱ្យចូលមកនៅក្នុងព្រះនគរ ទាល់តែគេធ្វើបាបព្រះអង្គ ធ្វើឱ្យព្រះនគរព្រះអង្គឱ្យខូចអស់ដូច្នេះ ? . នែលោកអ្នកទាំងអស់ ! ចូរលោកអ្នកប្រាប់យើង ជាប្រញាប់ក្នុងពេលនេះ ។

កាលនោះ ព្រះមាតាក្តី ព្រះបិតាក្តី ព្រះអគ្គមហេសីក្តី ព្រះញាតិទាំង ១៤ អង្គក្តី ពុំអាចឆ្លើយឱ្យការណ៍តែខ្លួនបានឡើយ សឹងតែទទួលសារភាពថា " យើងទាំងពួងខុសមែនមានទោសច្រើនមែន . តាមតែទ្រង់ព្រះមេត្តាព្រោសដល់យើងចុះ " ។

ព្រះបាទចិត្តរាជ កាលបានទ្រង់ព្រះសណ្តាប់ដូច្នោះ ទើប

ទ្រង់ព្រះរាជាបញ្ញាប្រើឱកញ្ញាសុខា ជាអ្នកសេនាឱ្យតាំងទីកុណ្ឌ (១) ពិធីឡើង ។ ព្រោះនោះ ហេតុតែវាសនាបារមីព្រះបាទចិន្តរាជចាស់ក្លា និងដោយសារឫទ្ធិព្រះឥសីទាំង ៣ រូប គឺព្រះបីតិ - អន្ធោ - វិរិយោលោកសូត្រសែកព្រះវេទមន្តឡើង. ព្រះខាន់ជ័យស្រីទាំង ៣ ក៏កើតឡើងកណ្ដាលទីកុណ្ឌពិធីនោះ. ទើបព្រះឥសីទាំងឡាយថ្វាយព្រះពរថា :

" កាលនេះ ជាកាលគួរ ដែលព្រះអង្គទ្រង់យាងចូលទៅកាន់ទីកុណ្ឌពិធីហើយ សូមព្រះអង្គទាញយកព្រះខាន់ជ័យស្រីទាំង ៣ អំពីទីកុណ្ឌពិធីនោះចុះ " ។

ព្រះបាទចិន្តរាជព្រះអង្គលូកព្រះហស្ត ទៅទាញយកព្រះខាន់ជ័យស្រីទាំង ៣ អំពីគំនរភ្លើងនៃកុណ្ឌពិធី សូម្បីតែនឹងបានក្ដៅព្រះហស្តបន្តិចបន្តួចក៏ទេ ។

ឯព្រះខាន់ជ័យស្រីទាំង ៣ នោះឈ្មោះ :

---

១ - ពិធីដែលគេធ្វើដោយជីករណ្ដៅជម្រៅ ១ ចំអាម ៥ ធ្នាប់ ដុតភ្លើងបូជាយញ្ញតាមលទ្ធិព្រាហ្មណ៍ ។

១ - គចង្គីបរិហារ មានបទព្រាត់ អាចញាំញីសត្រូវ បានដោយអស្ចើ ។

២ - វិទ្យុធបរិហារ មានបងបាស អាចសម្លុត់សម្លឹង សត្រូវឲ្យថ្លសម្លាត់ស្មោះបំបិទឲ្យកប្រើកពាង

៣ - សមុទ្ទេទបរិហារ មានបងវិចិត្រដោយកែវ ៧ ប្រការ អាចប្រហារសិរសាររៈផសត្រូវទាំងឡាយ ឲ្យដាច់ប្រចរន្ធាត កំបុតក ។

ព្រះពាលចិត្តរាជ . ទ្រង់ចាប់ព្រះខាន់ជ័យស្រីទាំងនោះ ព្រះរាជទានទៅអគ្គសេនាឈ្មោះឧកញ៉ាចិត្តបរិស្សុទ្ធិ៍ ដែលមានចិត្តថ្លាឥតកែវឲ្យជារាជតំណាង ដោយទ្រង់ព្រះរាជបញ្ជាថា ចូរអ្នកឯងសម្លាប់ព្រះពាលមោហរាជ ជាបិតាយើងដែលនាំឲ្យយើងវង្វេង. ព្រះនាងលោភទេវី ជាមាតាយើងដែលនាំឲ្យយើងលោភលន់ខ្លាំង. ព្រះនាងអវិជ្ជាទេវី ជាអគ្គមហេសីយើងដែលនាំឲ្យយើងងងឹតមុខជ្រប់ទៅតាមវា. ហើយចូរអ្នកឯងសម្លាប់ពួកពាលផងទាំង ១៤ នាក់ ដែលជាព្រះញាតិវង្សយើង ព្រោះ អ្នកទាំងនេះវាឲ្យសត្រូវខាងក្រៅចូលមកនៅក្នុងស្រុកយើង ឲ្យសត្រូវធ្វើឲ្យខូចព្រះនគរយើង យើងត្រូវតែសម្លាប់វាឲ្យ

អស់កុំឱ្យសល់ម្នាក់ ។

ឯឧកញ៉ាចិត្តបស្សទ្ធិ កាលទទួលព្រះរាជបញ្ជា ហើយក៏ប្រហារជីវិតជនអំពាលនោះ ឥតមានសល់ម្នាក់ ដោយព្រះខាន់ឈ្មោះសមុទ្ទេចប្បហារ ។

អស់លោកអ្នកអានអ្នកស្តាប់រឿងនេះ សូមកុំយល់ថា ព្រះពាទចិត្តរាជមានរូបជាមនុស្សប្រើគេឱ្យសម្លាប់មាតាបិតា ... មានរូបជាមនុស្សឡើយ មិនមែនឬទេ្នាះទេ ពីចិត្តសម្លាប់ចេតសិកដែលទុកមួបជាមាតាបិតា ... ដោយរឿងនេះលោកលើកយកធម៌ ជាធម្មាធិដ្ឋានមកតែងជាបុគ្គលាធិដ្ឋានជាន័យប្រៀបធៀបដើម្បីឱ្យអ្នកមានប្រាជ្ញាពិចយល់ពានបាយ ។ ឯព្រះពាទចិត្តរាជក៏គឺមូលចិត្តយើង . គេទាំងពួងទាំងឡាយ . ឥតរកាយក៏គឺរូបកាយយើងគេទាំងពួងនេះឯង . ទាំងព្រះមាតាព្រះបិតាព្រះអគ្គមហេសី និងព្រះញាតិ ១៤ អង្គក៏សុទ្ធតែជាអកុសលចេតសិកទាំងអស់ ។

អត្ថបទប្រៀបធៀប ដែលលោកលើកយកមកសំដែងនេះ ត្រូវគ្នានឹងអត្ថបទប្រៀបធៀប ដែលព្រះសម្ពុទ្ធទ្រង់សំដែងទុក

ក្នុងគម្ពីរខុទ្ទកនិកាយធម្មបទ ត្រង់បកិណ្ណកវគ្គថា :

មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច ខត្តិយេ រដ្ឋំ សានុចរំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ

បុគ្គលសម្លាប់តណ្ហាដូចមាតា . សម្លាប់អស្មិមានៈដូចបិតាសម្លាប់សស្សតទិដ្ឋិ ឧច្ឆេទទិដ្ឋិទាំងពីរ ដែលដូចខត្តិយរាជពីរព្រះអង្គ និងសម្លាប់អាយតនៈដូចដែន ព្រមទាំងនន្ទិរាគដូចស្មៀន តែងបានជាព្រាហ្មណ៍ ឥតមានទុក្ខ ទៅព្រះនិព្វាន ។

កាលឧកញ៉ាចិត្តបស្សទ្ធិ ប្រហារជីវិតជនទាំងនោះអស់ហើយ សម្តេចព្រះមហាសង្ឃរាជ ២ ព្រះអង្គ . ព្រះជីតុន ៣ រូប . ព្រះឥសី ៣ រូប . បុរោហិត ៣ រូប . មហាតម្រិត ៧ នាក់ និងអគ្គសេនា ១៩ នាក់ ក៏ត្រាវព្ធនិងសុំយាងព្រះបាទចិត្តរាជចេញចាកនគរកាយ ។

គ្រានោះ សម្តេចព្រះសង្ឃរាជថ្វាយព្រះពរថា :

ស្តេចព្រះអង្គយាងចុះមក អាឡាភាគទាំងឡាយក៏បាននាំព្រះអង្គទៅកាន់ព្រះធាតុកែវ ជាស្រុកព្រះអរិយបុគ្គល អាឡាភាគជាបន្ទុះស្ថេរ ហើយនាំថ្វាយព្រះអង្គទៅកាន់ក្នុងតម្បូរនេះ ៗ

ឯព្រះពោធិចិត្តរាជ កាលបើសម្តេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គ គឺព្រះសមាធិន្ទ្រិយ ព្រះបញ្ញិន្ទ្រិយ បានណែនាំ ( គោលគឺសមាធិ និងបញ្ញាបានកើតក្នុងចិត្តក៏ពិចារណាឃើញនូវសភាវធម៌ទាំងពួងតាមពិត ) ហើយ ទើបព្រះអង្គទ្រង់ពាក់តែងព្រះកាយដោយគ្រឿងទិព្វតែងភូសា ស្បែសស្បៃ សម្ភារ កង ព្រះហស្ថរាក់ ស្នាប់ព្រះឧរូ . ប្រកបទៅដោយកញ្ចប់ពិសេស គោលគឺព្រះពោធិបក្ខិយធម៌ ៣៧ ប្រការគឺ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ និងអដ្ឋង្គិកមគ្គ ៨ ជាគ្រឿងអលង្ការដ៏ល្អ ៗ រុងរឿង ហើយទ្រង់ពាក់នូវព្រះចម្រប់គ្រប់ម្រាមព្រះហស្ត ទាំង ១០ គោលគឺសិក្ខាបទ ១០ និងទ្រង់នូវព្រះមហាមកុដ គោលគឺសិក្ខាបទ ២២៧ និងទ្រង់នូវក្រោះពេជ្រសម្រាប់ព្រះតេជានុភាព គោលគឺព្រហ្មវិហារ ៤ ប្រការ គឺមេត្តា ករុណា មុទិតា

ឧបេក្ខា ហើយទ្រង់ក្រវាត់ព្រះខគ្គាវុធ ពោលគឺសមុច្ឆេទប្បហារ ដែលអាចកាប់កាត់ផ្តាច់បង់សត្រូវទាំងពួង ពោលគឺអកុសលទាំងអស់បាន ។ លុះទ្រង់គ្រឿងអលង្ការស្រេចហើយទើបទ្រង់យាងឡើងប្រថាប់លើព្រះធម្មរថ ពោលគឺព្រះសទ្ធម្ម ៨៤.០០០ ព្រះធម្មក្ខន្ធហើយក៏ទ្រង់និសីទនាការលើរតនបល្ល័ង្ក ជាព្រះវិធាំងដ៏ប្រកបដោយកែវ ៩ ប្រការ គឺព្រះនព្វលោកុត្តរធម៌ ៩ គឺមគ្គ ៤ ផល ៤ និព្វាន ១ ។ ឯធម្មរថនោះសឹងទឹមដោយសេះសិន្ធវជាតិអាជានេយ្យ ៤ គឺព្រះចតុប្បារិសុទ្ធិសីលទាំង ៤ គឺបាតិមោក្ខសំវរសីល ឥន្ទ្រិយសំវរសីល អាជីវបារិសុទ្ធិសីល និងបច្ចយសន្និស្សិតសីល ។ ធម្មអាជានេយ្យទាំង ៤ នេះក៏ទាញនូវព្រះធម្មរថឱ្យអណ្តែតត្រសែតឡើងលើនភាល័យ. ហើយព្រះបាទចិត្តរាជបរមក្សត្រ ព្រះអង្គប្រកបដោយឥទ្ធិវិទ្ធិ ៤ ប្រការ ពោលគឺឆន្ទិទ្ធិបាទ ( រិទ្ធិសម្រេចដោយសេចក្តីប្រាថ្នា ) វីរិយិទ្ធិបាទ ( រិទ្ធិសម្រេចដោយសេចក្តីព្យាយាម ). ចិត្តិទ្ធិបាទ ( រិទ្ធិសម្រេចដោយបញ្ញា ). ហើយទ្រង់បានត្រាស់បំពង់នូវព្រះញាណទាំង ៤ ប្រការ គឺបុព្វេនិវាសញ្ញាណ វេសារជ្ជញ្ញាណ អនាវរណញ្ញាណ និង សព្វញ្ញុតញ្ញាណ ។

វរជនទាំងឡាយ មានសម្តេចព្រះមហាសម្ពុរាជ ជាមគ្គទេសក៍ បាននាំព្រះពោធិចិត្តរាជទៅតាមមាគ៌ាទាំង ៤ គឺ សោតា សកទាគា - អនាគា -អរហត្ត ជាផ្លូវលោកុត្តរៈ របស់ព្រះអរិយបុគ្គលទាំងពួងពីបុរាណ ។ ព្រះពោធិចិត្តរាជក៏អណ្តែតត្រសែតលឿនលើវេហាស៍កណ្តាលហ្វូងយោធារហ័សពល បានទៅដល់ព្រះនគរកែវជាស្រុកស្ងប់ស្ងាត់ព្រាសចាកទុក្ខ ពោលគឺអមតមហានគរនិព្វាន ជាឋានបរមសុខប្រសើរផុតពីកណ្តាប់ដៃនៃមច្ចុរាជពីសេចក្តីស្លាប់ មច្ចុរាជមិនអាចតាមបំផ្លាញព្រះអង្គដូចពីមុនបាន ដោយហេតុព្រះអង្គយាងចូលស៊ប់ទៅក្នុងព្រះនគរកែវ គឺព្រះនិព្វានដ៏មានកំពែងកែវ ៧ (១) ជាន់ជិតជុំមាំមួនក្រៃពេក ជាព្រះនគរដ៏ព្រាសចាកទុក្ខទាំង ៤ កង គឺជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខឥតមិនយល់ឃើញឡើយ ។

---

១ សត្តពោជ្ឈង្គទាំង ៧ គឺសតិសម្ពោជ្ឈង្គ, ធម្មវិចយសម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ, បីតិសម្ពោជ្ឈង្គ, បស្សទ្ធិសម្ពោជ្ឈង្គ, សមាធិសម្ពោជ្ឈង្គ, ឧបេក្ខាសម្ពោជ្ឈង្គ ទុកជាកំពែងកែវ ៧ ជាន់ ។

ព្រះពោធិចិត្តរាជបរមក្សត្រ ព្រះអង្គបានគង់នៅជាបរមសុខ

ក្នុងឋាននិព្វាន ដូចបានពណ៌នាមក ។

អត្ថកថានេះ ពណ៌នាតាមលំអានបរមត្ថធម៌ ដែលព្រះសម្មាសម្ពុទ្ធបរមសាស្តាទ្រង់សំដែងអំពីកាយ និងចិត្ត ជាគ្រូ អប់រំទៀបត្រូវលោក ដើម្បីពន្យល់សាធុជនដែលបានអានបានស្តាប ឱ្យយល់ច្បាស់ទោសនៃជាតិ ជរា ព្យាធិ មរណៈ ដែលនាំសត្វឱ្យហែលវិលវល់ វង្វេងបន្តទៅក្នុងសមុទ្រនៃវដ្តសង្សារ ។

សាធុជនដែលបានអាន បានស្តាប់គួរសិក្សាព្រះធម៌នេះ ដើម្បីក្តោប កត់សំគាល់ចាំឱ្យជាក់ច្បាស់គ្រប់ន័យ ន័យត្រង់ណាដែលអត្ថកថានេះពោលសង្ខេប គឺគ្រាន់តែរាប់ឈ្មោះពុំបានប្រែ ពុំបានអធិប្បាយ ឬអធិប្បាយដោយខ្លី ៗ បើស្តាប់សេចក្តីពុំបាន ដើម្បីសាកសួរប្រឹក្សាអ្នកបណ្ឌិតបរមត្ថសាស្ត្រ ដែលជ្រួតជ្រាបក្នុងបរមត្ថធម៌ឱ្យលោកពន្យល់តទៅ ។

សូមសេចក្តីសុខ សេចក្តីចម្រើន កើតមាន ដល់លោកអ្នកអាន អ្នកស្តាប់ទាំងឡាយ សព្វ ៗ កាល !

ចាប _ ពិន

ចប់